# ព្រះវិហារបរិសុទ្ធដ៏ពិសិដ្ឋ --- ជាពន្លឺទៅកាន់ពិភពលោក

ប្រធាន ថូម៉ាស អេស ម៉នសុន

*ពរជ័យដ៏សំខាន់និងខ្ពស់បំផុត នៃសមាជិកភាពក្នុងសាសនាចក្រ គឺជាពរជ័យទាំងឡាយ ដែលយើងទទួលនៅក្នុងព្រះវិហារបរិសុទ្ធនៃព្រះ ។*

បងប្អូនប្រុសស្រីជាទីស្រឡាញ់ ខ្ញុំសូមសម្តែងសេចក្តីស្រឡាញ់ និងការស្វាគមន៍ដល់អ្នករាល់គ្នា ហើយសូមអធិស្ឋានឲ្យព្រះវរបិតាសួគ៌យើងដឹកនាំគំនិត និងបំផុសពាក្យសម្ដីរបស់ខ្ញុំ ពេលខ្ញុំនិយាយទៅកាន់អ្នកក្នុងថ្ងៃនេះ ។

ខ្ញុំសូមចាប់ផ្តើមដោយការសង្ខេបខ្លះៗនូវសារលិខិតដ៏វិសេស ដែលយើងបានស្តាប់ឮនៅព្រឹកនេះមកពីបងស្រីអាល់រ៉េដ និងប៊ីស្សព បើរតុន អំពីកម្មវិធីសុខុមាលភាពរបស់សាសនាចក្រ ។ ដូចដែលបានប្រាប់ថា នៅក្នុងឆ្នាំនេះ ជាគម្រប់ខួបលើកទី 75 នៃកម្មវិធីដ៏បំផុសគំនិតនេះ ដែលបានប្រទានពរដល់ជីវិតមនុស្សជាច្រើន ។ វាជាឯកសិទ្ធិរបស់ខ្ញុំ ដែលបានស្គាល់មនុស្សមួយចំនួន ដោយផ្ទាល់ ដែលបានដើរមុននៅក្នុងការប្រឹងប្រែងយ៉ាងខ្លាំង --- ជាមនុស្សនៃក្ដីមេត្តា និងការគិតទុកមុន ។

ដូចដែលប៊ីស្សព បើរតុន និងបងស្រីអាល់រ៉េដ បានប្រាប់ ប៊ីស្សពក្នុងវួដ មានការទទួលខុសត្រូវដើម្បីមើលថែដល់អ្នកខ្វះខាតទាំងឡាយដែលរស់នៅក្នុងព្រំដែនវួដរបស់គាត់ ។ ខ្ញុំមាននូវឯកសិទ្ធិធ្វើកិច្ចការទាំងនោះ ពេលខ្ញុំធ្វើជាប៊ីស្សពវ័យក្មេងក្នុងទីក្រុងសលត៍ លេក នៅវួដមួយដែលមានសមាជិកមួយពាន់ប្រាំបីរយនាក់ រួមមាន ស្ត្រីមេម៉ាយចំនួនប៉ែតសិបបួននាក់ ។ មានមនុស្សជាច្រើន ដែលត្រូវការជំនួយ ។ ខ្ញុំមានអំណរគុណខ្លាំងណាស់ចំពោះកម្មវិធីសុខុមាលភាពរបស់សាសនាចក្រ និងជំនួយរបស់សមាគមសង្គ្រោះ និងកូរ៉ុមបព្វជិតភាព ។

ខ្ញុំសូមប្រកាសថា កម្មវិធីសុខុមាលភាពនៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺត្រូវបានបំផុសគំនិតមកពីព្រះដ៏មានមហិទ្ធិឫទ្ធិ ។

បងប្អូនប្រុសស្រី ឥឡូវសន្និសីទនេះបានកំណត់ចំណាំជារយៈពេលបីឆ្នាំ ចាប់តាំងពីខ្ញុំត្រូវបានគាំទ្រជាប្រធាននៃសាសនាចក្រ ។ ប្រាកដណាស់រយៈពេលបីឆ្នាំនេះ មាននូវការរវល់ និងឧបសគ្គជាច្រើន ប៉ុន្តែក៏មានពរជ័យរាប់មិនអស់ផងដែរ ។ ឱកាសដែលខ្ញុំមានក្នុងការឧទ្ទិសឆ្លង និងឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធសារជាថ្មី គឺជាពរជ័យដ៏រីករាយ និងពិសិដ្ឋបំផុតក្នុងចំណោមពរជ័យទាំងឡាយ ហើយខ្ញុំចង់និយាយទៅកាន់អ្នកថ្ងៃនេះអំពីព្រះវិហារបរិសុទ្ធ ។

អំឡុងពេលសន្និសីទទូទៅខែតុលា ឆ្នាំ 1902 ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានចាប់ផ្តើមសុន្ទរកថារបស់លោកដោយសម្តែងចេញនូវក្តីសង្ឃឹមថា ថ្ងៃណាមួយ យើងនឹងមាន « ព្រះវិហារបរិសុទ្ធជាច្រើនសាងសង់នៅកន្លែងផ្សេងៗក្នុង[ ពិភពលោក ] ដែលនឹងផ្ដល់នូវភាពងាយស្រួលដល់មនុស្សទូទៅ » ។[1]

អំឡុងពេល 150 ឆ្នាំដំបូង បន្ទាប់ពីការរៀបចំសាសនាចក្រ ចាប់ពីឆ្នាំ 1830 ដល់ឆ្នាំ 1980 មានព្រះវិហារបរិសុទ្ធចំនួន 21 កន្លែង ត្រូវបានសង់ឡើង រួមមានព្រះវិហារបរិសុទ្ធនៅ ខឺតឡង់ អូហៃអូ និងណៅវូ រដ្ឋអ៊ីលលីណោយ ។ ផ្ទុយទៅវិញ ក្នុងរយៈពេលតែ 30 ឆ្នាំប៉ុណ្ណោះគឺ ចាប់តាំងពីឆ្នាំ 1980 មក គឺព្រះវិហារបរិសុទ្ធចំនួន 115 កន្លែងត្រូវបានសាងសង់ និងធ្វើការឧទ្ទិសឆ្លង ។

ព្រមជាមួយនឹងការប្រកាសអំពីព្រះវិហារបរិសុទ្ធថ្មីចំនួនបីទៀតកាលពីម្សិលមិញ ហើយមានព្រះវិហារបរិសុទ្ធ 26 កន្លែងទៀតដែលកំពុងតែស្ថិតនៅក្នុងដំណាក់នៃការសាងសង់ ឬត្រៀមនឹងធ្វើការសាងសង់ ។ ចំនួននេះនឹងបន្តកើនឡើង ។

គោលដៅ ដែលប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានសង្ឃឹមកាលពីឆ្នាំ 1902 កំពុងតែក្លាយជាការពិតហើយ ។ បំណងប្រាថ្នារបស់យើង គឺត្រូវធ្វើឲ្យមានព្រះវិហារបរិសុទ្ធសម្រាប់សមាជិករបស់យើង ។

មានព្រះវិហារបរិសុទ្ធមួយកំពុងតែសាងសង់ថ្មីៗនេះ នៅម៉ាណាអុស ប្រទេស ប្រេស៊ីល ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានអានអំពីក្រុមសមាជិកជាងមួយរយនាក់ ដែលបានចាកចេញពីម៉ាណាអុស ដែលស្ថិតនៅកណ្តាលព្រៃលិចទឹកអាម៉ាហ្សូន ធ្វើដំណើរទៅព្រះវិហារបរិសុទ្ធដែលនៅជិតបំផុត ដែលស្ថិតនៅទីក្រុង សៅផាឡូ ប្រទេសប្រេស៊ីល --- ចម្ងាយប្រហែល 4,000 គីឡូម៉ែត្រពីម៉ាណាអុស ។ ពួកបរិសុទ្ធស្មោះត្រង់ទាំងនោះបានធ្វើដំណើរតាមទូករយៈពេលបួនថ្ងៃ លើទន្លេអាម៉ាហ្សូន ហើយទៅទន្លេមួយទៀត ។ បន្ទាប់ពីបានបញ្ចប់ការធ្វើដំណើរតាមទឹកនេះ ពួកគេបានឡើងជិះឡានក្រុងរយៈពេលបីថ្ងៃ

ទៀត ដោយមានមានអាហារបរិភោគតែបន្តិចបន្តួចប៉ុណ្ណោះ ហើយគ្មានកន្លែងសម្រាកស្រួលទេ ។ បន្ទាប់ពីរយៈពេលប្រាំពីរយប់ប្រាំពីរថ្ងៃ ពួកគេបានមកដល់ព្រះវិហារបរិសុទ្ធនៅ សៅផាឡូ ជាទីកន្លែងដែលពិធីបរិសុទ្ធដ៏អស់កល្បត្រូវធ្វើឡើង ។

ប្រាកដណាស់ ការធ្វើដំណើរត្រឡប់ទៅវិញ របស់ពួកគេគឺមានការលំបាកដូចគ្នា ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានទទួលពិធីបរិសុទ្ធ និងពរជ័យនៃព្រះវិហារបរិសុទ្ធ ហើយទោះបីជាក្នុងកាបូបពួកគេគ្មាននៅសល់ប្រាក់ក្តី ក៏ពួកគេបានពោរពេញទៅដោយអារម្មណ៍នៃព្រះវិហារបរិសុទ្ធ ហើយមានអំណរគុណចំពោះពរជ័យទាំងឡាយ ដែលពួកគេបានទទួល ។ 2 ប៉ុន្មានឆ្នាំក្រោយមក ឥឡូវនេះ សមាជិករបស់យើង នៅ ម៉ាណាអុស កំពុងតែរីករាយ នៅពេលពួកគេមើលព្រះវិហារបរិសុទ្ធរបស់ពួកគេចាប់ផ្តើមសាងសង់ នៅលើច្រាំងទន្លេ រីយ៉ូ ណេគ្រូ នោះ ។ ព្រះវិហារបរិសុទ្ធជាច្រើន បាននាំក្តីអំណរដល់សមាជិកបរិសុទ្ធ ហើយស្មោះត្រង់របស់យើង នៅកន្លែងណាដែលសាងសង់ឡើង ។

មានតែរបាយការណ៍ពីការធ្វើពលិកម្មជាច្រើនក្នុងការទទួលបានពរជ័យនៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះប៉ុណ្ណោះ តែងតែប៉ះដល់ដួងចិត្តខ្ញុំ ហើយនាំឲ្យខ្ញុំនឹកអរគុណសារជាថ្មីចំពោះព្រះវិហារបរិសុទ្ធជានិច្ច ។

ខ្ញុំសូមចែកចាយនឹងអ្នកនូវរឿងអំពី ទីហ៊ី និងតារ៉ារ៉ែណា មូថាំ និងកូនៗទាំងដប់នាក់របស់ពួកគេ ។ គ្រួសារនេះបានចូលសាសនាចក្រនៅដើម ទសវត្សរ៍ឆ្នាំ 1960 ពេលអ្នកផ្សព្វផ្សាយសាសនា មកដល់កោះរបស់ពួកគេ ដែលមានចម្ងាយប្រហែល 160 គីឡូម៉ែត្រភាគខាងត្បូងនៃកោះតាហ៊ីទី ។ មិនយូរប៉ុន្មាន ពួកគេបានចាប់ផ្តើមចង់បានពរជ័យនៃការផ្សារភ្ជាប់គ្រួសារដ៏អស់កល្បជានិច្ច នៅក្នុងព្រះវិហារបរិសុទ្ធ ។

នៅពេលនោះ ព្រះវិហារបរិសុទ្ធដែលនៅជិតនឹងគ្រួសារ មូថាំ ជាងគេបំផុតគឺ ព្រះវិហារបរិសុទ្ធ ហាមិលតុន នូហ្សីឡែន ដែលមានចម្ងាយច្រើនជាង 4,000 គីឡូម៉ែត្រ ទៅប៉ែកខាងអាគ្នេយ៍ ដែលអាចទៅដល់តាមរយៈការធ្វើដំណើរតាមយន្តហោះ ដែលមានតម្លៃថ្លៃប៉ុណ្ណោះ ។ គ្រួសារ មូថាំ ដ៏ធំ ដែលមានការលំបាកយ៉ាងខ្លាំង ហើយរស់នៅយ៉ាងក្រីក្រដោយសារការដាំដុះដ៏តូចមួយ គ្មានប្រាក់ដើម្បីចំណាយថ្លៃយន្តហោះទេ ក៏គ្មានឱកាសណា ដើម្បីរកការងារនៅលើកោះប៉ាស៊ីភិចរបស់ពួកគេដែរ ។ ដូច្នេះបងប្រុស មូថាំ និងកូនប្រុសរបស់គាត់ ជីរ៉ាដ បានធ្វើការសម្រេចចិត្តដ៏លំបាក ដើម្បីទៅធ្វើការជាមួយនឹងកូនប្រុសម្នាក់ទៀត នៅ នូខាឡេដូនៀ ចម្ងាយប្រហែលជា 48 គីឡូម៉ែត្រ ។ បុរសបីនាក់ក្នុងគ្រួសារ មូថាំ បានធ្វើការរយៈពេលបួនឆ្នាំ ។ បងប្រុស មូថាំ ត្រឡប់មកលេងផ្ទះតែម្នាក់ឯងរយៈពេលខ្លី ម្តងក្នុងមួយឆ្នាំ ទុកឲ្យកូនប្រុសនៅ នូខាឡេដូនៀ ។

បន្ទាប់ពីរយៈពេលបួនឆ្នាំនៃការធ្វើការយ៉ាងនឿយហត់មក បងប្រុស មូថាំ និងកូនប្រុសរបស់គាត់បានសន្សំប្រាក់ល្មមនឹងនាំគ្រួសារទៅព្រះវិហារបរិសុទ្ធនូហ្សីឡែន ។ ទាំងអស់គ្នាបានទៅទីនោះ លើកលែងតែកូនស្រីម្នាក់ចេញ ។ ពួកគេបានផ្សារភ្ជាប់សម្រាប់ជីវិតនេះ និងភាពអស់កល្បជានិច្ចដែលជាបទពិសោធន៍មិនអាចពិពណ៌នាបាន និងប្រកបដោយក្តីអំណរ ។

បងប្រុស មូថាំ បានត្រឡប់ពីព្រះវិហារបរិសុទ្ធទៅកាន់ នូខាឡេនៀ ត្រង់តែម្តង ដើម្បីធ្វើការពីរឆ្នាំទៀត ដើម្បីបង់ថ្លៃសម្រាប់កូនស្រីម្នាក់ ដែលមិនបានទៅព្រះវិហារបរិសុទ្ធជាមួយពួកគាត់ --- ជាកូនស្រីដែលបានរៀបការរួចហើយ ដែលមានកូន និងប្តីរបស់នាង ។

នៅក្នុងឆ្នាំក្រោយៗមក បងប្រុស និងបងស្រី មូថាំបានសម្រេចចិត្តបម្រើនៅក្នុងព្រះវិហារបរិសុទ្ធ ។ ដល់ពេលនោះ ព្រះវិហារបរិសុទ្ធ ប៉ាពីតេ តាហ៊ីទី ត្រូវបានសាងសង់ និងឧទ្ទិសឆ្លង ពួកគេបានបម្រើបេសកកម្មចំនួនពីរនៅទីនោះ ។[3]

បងប្អូនប្រុសស្រី ព្រះវិហារបរិសុទ្ធមានន័យលើសពីថ្មដា និងថ្មបាយអទៅទៀត ។ ព្រះវិហារបរិសុទ្ធមានពេញទៅដោយមនុស្សដែលមានជំនឿ និងការតមអាហារ ។ ព្រះវិហារបរិសុទ្ធ ត្រូវបានសាងសង់ឡើងដោយការសាកល្បង និងទីបន្ទាល់ ។ ព្រះវិហារបរិសុទ្ធត្រូវបានញែកចេញ តាមរយៈការពលិកម្ម និងការបម្រើ ។

ព្រះវិហារបរិសុទ្ធទីមួយដែលត្រូវសាងសង់ក្នុងការកាន់កាប់គ្រួតគ្រានេះ គឺព្រះវិហារបរិសុទ្ធ ខឺតឡង់ រដ្ឋអូហៃអូ ។ ពួកបរិសុទ្ធនៅគ្រានោះ ក្រីក្រ ប៉ុន្តែព្រះអម្ចាស់បានបញ្ជាថា ត្រូវសង់ព្រះវិហារបរិសុទ្ធ ដូច្នេះពួកគេបានសង់ ។ អែលឌើរ ហ៊ីប៊ើរ ស៊ី គិមបុល បានសរសេរពីបទពិសោធន៍នេះថា « ព្រះអម្ចាស់ស្គាល់ទិដ្ឋភាពនៃភាពក្រីក្រ ការលំបាក និងទុក្ខព្រួយ ដែលយើងឆ្លងកាត់ដើម្បីសម្រេចការសាងសង់ព្រះវិហារបរិសុទ្ធនេះ » ។[4] បន្ទាប់មក ពេលអ្វីៗត្រូវបានបញ្ចប់សព្វគ្រប់ នោះពួកបរិសុទ្ធត្រូវបានបង្ខំឲ្យចាកចេញពីអូហៃអូ និងព្រះវិហារបរិសុទ្ធជាទីស្រឡាញ់របស់ពួកគេ ។ ទីបំផុត ពួកគេបានរកឃើញទី

ជម្រក --- ទោះជាជម្រកនោះនៅជាបណ្ដោះអាសន្ន ---តាមមាត់ច្រាំងទន្លេមីស៊ីស៊ីពីក្នុងរដ្ឋ អិលលីណោយក្ដី ។ពួកគេបានដាក់ឈ្មោះកន្លែងតាំងលំនៅរបស់ពួកគេថា ណៅវូ ហើយស្ម័គ្រចិត្តដើម្បីអ្វីៗគ្រប់យ៉ាងម្ដងទៀត ដោយមានជាប់នូវក្ដីជំនឿរបស់ពួកគេ ពួកគេសង់ព្រះវិហារបរិសុទ្ធមួយទៀតថ្វាយព្រះរបស់ពួកគេ ។

ការធ្វើទុក្ខបុកម្នេញកើតឡើង ពេលព្រះវិហារបរិសុទ្ធណៅវូជិតសង់រួច ពួកគេត្រូវបានបណ្ដេញ ឲ្យចេញពីផ្ទះជាថ្មីម្ដងទៀត ហើយពួកគេបានទៅរកទីជម្រកនៅកន្លែងវាលខ្សាច់ ដែលគ្មាននរណាម្នាក់ចង់ទៅ ។

ការពុះពារ និងការពលិកម្មបានចាប់ផ្ដើមជាថ្មីម្ដងទៀត នៅពេលពួកគេធ្វើការរយៈពេល 40 ឆ្នាំ ដើម្បីសង់ព្រះវិហារបរិសុទ្ធ សលត៍ លេក ដែលឈរយ៉ាងស្ដឹមស្ដៃ នៅលើទិសខាងត្បូងនៃយើងទាំងអស់គ្នា ដែលនៅទីនេះនាថ្ងៃនេះ ក្នុងមជ្ឈមណ្ឌលសន្និសីទ ។

មានជាប់នឹងកម្រិតនៃការពលិកម្មមួយចំនួន ក្នុងការសាងសង់ព្រះវិហារបរិសុទ្ធ និងការចូលរួមក្នុងព្រះវិហារបរិសុទ្ធ ។ មានសមាជិកយ៉ាងច្រើន ដែលបានធ្វើការ និងពុះពារ ដើម្បីទទួលបានពរជ័យសម្រាប់ខ្លួនគេ និងគ្រួសាររបស់ពួកគេ ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធនៃព្រះ ។

ហេតុអ្វីបានជាមានមនុស្សយ៉ាងច្រើន ស្ម័គ្រចិត្តដើម្បីលះបង់យ៉ាងច្រើន ដើម្បីទទួលពរជ័យនៃព្រះវិហារបរិសុទ្ធ ? អ្នកដែលយល់ពីពរជ័យដ៏អស់កល្បជានិច្ចមកពីព្រះវិហារបរិសុទ្ធដឹងថា គ្មានការពលិកម្មណាមួយមហិមាខ្លាំងពេក គ្មានតម្លៃណាធ្ងន់ធ្ងរពេក និងគ្មានការពុះពារណាលំបាកពេក ក្នុងការទទួលពរជ័យទាំងនោះទេ ។ពួកគេនឹងធ្វើដំណើរទៅមិនថាឆ្ងាយប៉ុណ្ណា យកឈ្នះលើឧបសគ្គទាំងអស់មិនថាច្រើនប៉ុណ្ណា ឬ ស៊ូទ្រាំគ្រប់ភាពមិនងាយស្រួលទាំងអស់ ។

ពួកគេយល់ថា ពិធីបរិសុទ្ធនៃការសង្គ្រោះ ដែលបានទទួលក្នុងព្រះវិហារបរិសុទ្ធ ដែលអនុញ្ញាតឲ្យយើងត្រឡប់ទៅព្រះវរបិតាសួគ៌នៅថ្ងៃមួយក្នុងទំនាក់ទំនងគ្រួសារអស់កល្បជានិច្ច និងត្រូវបានប្រទានឲ្យនូវពរជ័យ និងអំណាចមកពីទីខ្ពស់ គឺមានតម្លៃគ្រប់ពលិកម្ម និងការខិតខំទាំងអស់ ។

សព្វថ្ងៃនេះ យើងភាគច្រើនមិនបានរងទុក្ខការលំបាកខ្លាំងៗ ដើម្បីចូលរួមក្នុងព្រះវិហារបរិសុទ្ធ ទេ ។ សមាជិកក្នុងសាសនាចក្រ 85 ភាគរយ ឥឡូវរស់នៅក្នុងរង្វង់ 300 គីឡូម៉ែត្រពី ព្រះវិហារបរិសុទ្ធ ហើយមានគ្នាយើងច្រើនណាស់ដែលរស់នៅកាន់តែជិត ។ បើអ្នកបានទៅព្រះវិហារបរិសុទ្ធសម្រាប់ខ្លួនអ្នកហើយ ហើយបើអ្នករស់នៅជិតនឹងព្រះវិហារបរិសុទ្ធ ការពលិកម្មអ្នកអាចជាការញែកពេលពីជីវិតដ៏រវល់របស់អ្នក ដើម្បីទៅព្រះវិហារបរិសុទ្ធជាទៀងទាត់ ។ មានកិច្ចការច្រើនណាស់ដែលត្រូវធ្វើក្នុងព្រះវិហារបរិសុទ្ធរបស់យើង ជំនួសអ្នកដែលនៅរង់ចាំឯម្ខាងទៀតនៃវាំងនន ។ នៅពេលយើងធ្វើកិច្ចការសម្រាប់ពួកគេ នោះយើងនឹងដឹងថា យើងបានធ្វើសម្រេចនូវអ្វីដែលពួកគេមិនធ្វើដោយខ្លួនឯង ។

ក្នុងការប្រកាសដ៏មុតមាំមួយ ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានថ្លែងថា ៖ « តាមរយៈការខិតខំរបស់យើងជំនួសពួកគេ នោះច្រវាក់នៃទាសភាពនឹងជ្រុះចេញពីពួកគេ ហើយភាពងងឹតដែលហ៊ុមព័ទ្ធពួកគេ នឹងរសាត់ចេញ ដើម្បីពន្លឺអាចបំភ្លឺមកលើពួកគេ ហើយពួកគេនឹងស្ដាប់ឮនៅក្នុងពិភពវិញ្ញាណនៃកិច្ចការដែលត្រូវបានធ្វើជំនួសពួកគេដោយកូនចៅពួកគេនៅទីនេះ ហើយនឹងរីករាយជាមួយអ្នក ក្នុងការធ្វើនូវកាតព្វកិច្ចទាំងនេះរបស់អ្នក » ។[5] បងប្អូនប្រុសស្រីរបស់ខ្ញុំ កិច្ចការនោះជារបស់យើងដើម្បីធ្វើ ។

នៅក្នុងគ្រួសាររបស់ខ្ញុំ បទពិសោធន៍ដ៏ពិសិដ្ឋមួយចំនួន និងមានតម្លៃបំផុតរបស់យើង គឺកើតឡើងពេលយើងបានចូលរួមជាមួយគ្នាក្នុងព្រះវិហារបរិសុទ្ធ ដើម្បីធ្វើពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ សម្រាប់ជីដូនជីតាដែលបានស្លាប់ទៅរបស់យើង ។

បើអ្នកមិនទាន់បានទៅព្រះវិហារបរិសុទ្ធ ឬបើអ្នក *បានទៅ* ប៉ុន្តែថ្មីៗនេះ គ្មានភាពសក្ដិសម កាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធ គោលដៅសំខាន់បំផុតរបស់អ្នកគឺត្រូវខិតខំដើម្បីមានភាពសក្ដិសមទៅព្រះវិហារបរិសុទ្ធ ។ ការពលិកម្មរបស់អ្នកអាចនាំឲ្យជីវិតរបស់អ្នក ដើរស្របជាមួយនឹងអ្វីដែលតម្រូវឲ្យមាន ដើម្បីទទួលប័ណ្ណចូលព្រះវិហារបរិសុទ្ធ ប្រហែលជាត្រូវលះបង់ទម្លាប់ដែលធ្វើឲ្យអ្នកមិនសក្ដិសមជាយូរនោះចោល ។ អាចជាការមានសេចក្ដីជំនឿ និងការលត់ដំខ្លួន ដើម្បីបង់ដង្វាយមួយភាគក្នុងដប់របស់អ្នក ។ អ្វីៗដែលតម្រូវ ដើម្បីមានភាពសក្ដិសមចូលព្រះវិហារបរិសុទ្ធរបស់ព្រះ ។ ចូរទទួលប័ណ្ណចូលព្រះវិហារបរិសុទ្ធ ហើយកាន់វាដូចជាទ្រព្យដ៏មានតម្លៃព្រោះវាជាទ្រព្យដ៏មានតម្លៃ ។

ហេតុដល់អ្នកបានចូលក្នុងដំណាក់នៃព្រះអម្ចាស់ ហើយបានទទួលគ្រប់ពរជ័យដែលរង់ចាំអ្នកនៅទីនោះ នោះអ្នកមិនបានទទួលអ្វីៗទាំងអស់ ដែលសាសនាចក្របានផ្ដល់ឲ្យទេ ។ ពរជ័យដ៏សំខាន់និងខ្ពស់បំផុត នៃសមាជិកភាពក្នុងសាសនាចក្រ គឺជាពរជ័យទាំងឡាយ ដែលយើងទទួលនៅក្នុងព្រះវិហារបរិសុទ្ធនៃព្រះ ។

ឥឡូវ មិត្តយុវវ័យរបស់ខ្ញុំដែលស្ថិតក្នុងវ័យជំទង់ សូមមានព្រះវិហារបរិសុទ្ធ ក្នុងគោលដៅអ្នកជានិច្ច ។ សូមកុំធ្វើអ្វីដែលនឹងរារាំងអ្នកមិនឲ្យចូលក្នុងទ្វារព្រះវិហារបរិសុទ្ធ ហើយទទួលពរជ័យដ៏ពិសិដ្ឋ និងអស់កល្បជានិច្ចនៅទីនោះឡើយ ។ ខ្ញុំសូមសរសើរដល់អ្នក ដែលបានទៅព្រះវិហារបរិសុទ្ធជាទៀងទាត់រួចហើយ ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់អ្នកស្លាប់ ដែលបានក្រោកឡើងពីព្រលឹម ដើម្បីអ្នកអាចចូលរួមក្នុងពិធីបុណ្យជ្រមុជទឹក មុនពេលចូលរៀន ។ ខ្ញុំអាចគិតថាគ្មានអ្វីល្អជាងនោះទេ សម្រាប់ការចាប់ផ្ដើមនៅថ្ងៃនោះ ។

ចំពោះឪពុកម្ដាយនៃកូនតូចៗ ខ្ញុំសូមចែកចាយនឹងអ្នកនូវជំបូន្មានឈ្លាសវៃមួយចំនួនមកពីប្រធាន ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល គាត់មានប្រសាសន៍ថា ៖ « វានឹងជារឿងដ៏ល្អមួយ បើ ...ឪពុកម្ដាយ មានរូបភាពព្រះវិហារបរិសុទ្ធក្នុងបន្ទប់ដេកក្នុងផ្ទះរបស់ពួកគេ ដើម្បីឲ្យ [ កូនៗរបស់ពួកគេ] ចាប់តាំងពីពេល [ ពួកគេ ] នៅជាទារកអាចមើលរូបភាពនោះជារៀងរាល់ ថ្ងៃ [ រហូត ] ដល់វាក្លាយទៅជាចំណែកមួយនៃជីវិត [ របស់ពួកគេ ] ។

នៅពេល [ ពួកគេ ] ឈានចូលដល់អាយុដែល [ ពួកគេ ] ចាំបាច់ត្រូវធ្វើការសម្រេចចិត្តដ៏សំខាន់ [ អំពីការទៅព្រះវិហារបរិសុទ្ធ ] នោះគេនឹងបានសម្រេចចិត្តរួចស្រេចហើយ » ។ [6]

កុមាររបស់យើងច្រៀងក្នុងថ្នាក់កុមារថា ៖

*ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ*
*ខ្ញុំនឹងទៅទីនោះថ្ងៃមួយ*
*ខ្ញុំនឹងធ្វើសេចក្ដីសញ្ញាជាមួយនឹងបិតាខ្ញុំ*
*ខ្ញុំនឹងសន្យាថាគោរពតាម ។* [7]

ខ្ញុំសូមអង្វរដល់អ្នកឲ្យបង្រៀនដល់កូនៗរបស់អ្នកអំពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធ ។

ពិភពលោកអាចជាកន្លែងមានឧបសគ្គ និងលំបាក ដើម្បីរស់នៅ ។ យើងជារឿយៗ ត្រូវបានហ៊ុមព័ទ្ធដោយអ្វី ដែលនឹងទាញយើងទម្លាក់ចុះ ។ នៅពេលអ្នក និងខ្ញុំទៅដំណាក់ដ៏បរិសុទ្ធនៃព្រះ នៅពេលយើងចងចាំសេចក្ដីសញ្ញា ដែលយើងបានធ្វើនៅក្នុងនោះ នោះយើងនឹងកាន់តែអាចទ្រាំទ្រនូវការសាកល្បងគ្រប់យ៉ាង ហើយយកឈ្នះលើការល្បួងនីមួយៗ ។ នៅក្នុងកន្លែងដ៏ពិសិដ្ឋនេះ យើងនឹងរកឃើញសេចក្ដីសុខសាន្ត យើងនឹងត្រូវបានរំលឹក និងការពារ ។

ឥឡូវនេះ បងប្អូនប្រុសស្រីរបស់ខ្ញុំ ខ្ញុំសូមប្រាប់អំពីព្រះវិហារបរិសុទ្ធមួយទៀត មុនពេលខ្ញុំបញ្ចប់ ។ នៅក្នុងពេលអនាគតឆាប់ៗនេះ នៅពេលព្រះវិហារបរិសុទ្ធថ្មី ត្រូវបានសាងសង់នៅជុំវិញពិភពលោក ព្រះវិហារបរិសុទ្ធមួយនឹងសង់ឡើងនៅក្នុងទីក្រុង ដែលមានអាយុជាងមួយរយម្ភៃប្រាំឆ្នាំមកហើយ ។ ខ្ញុំនិយាយអំពីព្រះវិហារបរិសុទ្ធ ដែលឥឡូវកំពុងតែសាងសង់នៅក្នុងទីក្រុង រ៉ូម ប្រទេសអ៊ីតាលី ។ គ្រប់ព្រះវិហារបរិសុទ្ធគឺជាដំណាក់នៃព្រះដែលបំពេញមុខងារដូចគ្នា ហើយជាពរជ័យ និងពិធីបរិសុទ្ធដូចគ្នា ។ ព្រះវិហារបរិសុទ្ធរ៉ូម ជាពិសេសត្រូវបានសង់ឡើងនៅទីតាំង ប្រវត្តិសាស្ត្របំផុតមួយក្នុងពិភពលោក ជាទីក្រុងមួយដែលសាវកពេត្រុស និងសាវកប៉ុលពីបុរាណ បានផ្សាយដំណឹងល្អនៃព្រះគ្រីស្ទ ហើយជាកន្លែងដែលពួកគាត់ម្នាក់ៗ ត្រូវបានគេសម្លាប់។

ខែតុលាមុន នៅពេលយើងប្រមូលផ្ដុំគ្នានៅទីតាំងដាច់ស្រយាលគួរឲ្យស្រឡាញ់មួយ នៅជ្រុងខាងប៉ែកឥសាន្តនៃទីក្រុងរ៉ូម វាគឺជាឱកាសរបស់ខ្ញុំ ដើម្បីផ្ដល់ការអធិស្ឋានឧទ្ទិសឆ្លងមួយ នៅពេលយើងរៀបចំជីកដី ។ ខ្ញុំទទួលអារម្មណ៍បញ្ជាក់ឲ្យហៅព្រឹទ្ធសភាអ៊ីតាលី លូស៊្យូ ម៉ាឡាន និង អនុចៅហ្វាយក្រុងរ៉ូម គី្សេប៉េ ស៊ីយ៉ាឌី មកចូលរួមក្នុងចំណោមអ្នកទីមួយ ដែលនឹងជីកដី ។ ពួកគាត់ម្នាក់ៗ មានចំណែកក្នុងការសម្រេចចិត្តអនុញ្ញាតឲ្យយើង សង់ព្រះវិហារបរិសុទ្ធ ក្នុងទីក្រុងរបស់ពួកគាត់ ។

នៅថ្ងៃបន្ទាប់នោះមេឃស្រទំ ប៉ុន្តែក្តៅ ហើយទោះបីជាភ្លៀងបម្រុងធ្លាក់មក ក៏មានតែពីរបីតំណក់ប៉ុណ្ណោះ ។ នៅប្រទេស អ៊ីតាលី ពេលក្រុមចម្រៀងដ៏អស្ចារ្យច្រៀង នោះកម្លាំងដ៏អស្ចារ្យនៃ « ព្រះវិញ្ញាណនៃព្រះ » ធ្វើឲ្យមនុស្សគ្រប់គ្នាទទួលអារម្មណ៍ដូចជាផែនដី និងស្ថានសួគ៌ ចូលរួមក្នុងទំនុកដំកើងសរសើរដ៏រុងរឿង និងដឹងគុណចំពោះព្រះ ដ៏មានមហិទ្ធិឫទ្ធិ ។ ទឹកភ្នែកបានស្រក់ចុះមក ។

នៅថ្ងៃមួយ ពួកស្មោះត្រង់ក្នុង « ទីក្រុងអស់កល្ប » នេះ នឹងទទួលពិធីបរិសុទ្ធដ៏អស់កល្បក្នុងដំណាក់ដ៏បរិសុទ្ធរបស់ព្រះ ។

ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏អស់កល្បចំពោះព្រះវរបិតាសួគ៌ ចំពោះព្រះវិហារបរិសុទ្ធដែលឥឡូវនេះបានសាងសង់ក្នុងទីក្រុងរ៉ូម និងគ្រប់ព្រះវិហារបរិសុទ្ធរបស់យើងនៅគ្រប់ទីកន្លែង ។ ព្រះវិហារបរិសុទ្ធនីមួយៗ ឈរជាពន្លឺទៅកាន់ពិភពលោក ជាការបង្ហាញពីទីបន្ទាល់របស់យើងថា ព្រះជាព្រះវរបិតាសួគ៌របស់យើងមានព្រះជន្មរស់ ថាទ្រង់មានព្រះទ័យចង់ប្រទានពរដល់យើង ប្រាកដណាស់ ដើម្បីប្រទានពរដល់បុត្រាបុត្រីរបស់ទ្រង់ នៅគ្រប់ជំនាន់ទាំងអស់ ។ ព្រះវិហារបរិសុទ្ធនីមួយៗរបស់យើង គឺជាការបង្ហាញពីទីបន្ទាល់របស់យើងថា ជីវិតបន្ទាប់ពីសេចក្តីស្លាប់ គឺមានពិត និងជាក់ច្បាស់ដូចជាជីវិតរបស់យើងលើផែនដីនេះដែរ ។

បងប្អូនប្រុសស្រីរបស់ខ្ញុំ សូមយើងធ្វើពលិកម្មដែលចាំបាច់គ្រប់យ៉ាង ដើម្បីចូលព្រះវិហារបរិសុទ្ធ ហើយមានវិញ្ញាណនៃព្រះវិហារបរិសុទ្ធនៅក្នុងដួងចិត្ត និងគេហដ្ឋានរបស់យើង ។ សូមឲ្យយើងធ្វើតាមដានជើងព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនៃយើង ជាព្រះយេស៊ូវគ្រីស្ទ ដែលធ្វើពលិកម្មដ៏គ្មានទីបញ្ចប់សម្រាប់យើង ដើម្បីយើងមានជីវិតដ៏អស់កល្បជានិច្ច និងការលើកតម្កើងនៅក្នុងនគររបស់ព្រះវរបិតាសួគ៌របស់យើង ។ខ្ញុំសូមអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ  អាម៉ែន ។

កំណត់ចំណាំ

1. នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1902 ។
2. សូមមើល Church News ថ្ងៃទី 13 ខែ មិនា ឆ្នាំ 1993 ។
3. សូមមើល Church News ថ្ងៃទី 16 ខែ មិនា ឆ្នាំ 1996 ។
4. អ័រសុន អែហ្វ វីតនី Life of Heber C. Kimball ( ឆ្នាំ 1945 ) ទំព័រ 67--68 ។
5. នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1916 ទំព័រ 6 ។
6. The Teachings of Spencer W. Kimball បានកែសម្រួលដោយ អែតវើត អិល ឃីមប៊ល  301 ។
7. ជេនីស ខាប ភែរី ឆ្នាំ 1938 ©1980 ដោយ ជេនីស ខាប ភែរី Children′s Songbook of The Church of Jesus Christ of Latter-day Saints ទំព័រ 95 ។